ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY


សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ការបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនីតិវិធីជួញដូររបស់ផ្សារមូលបត្រកម្ពុជា

INFORMING KNOWLEDGE RELATED TO TRADING PROCEDURES OF THE CAMBODIAN SECURITIES EXCHANGE

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា
VANDA UNIVERSITY

## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ការបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនីតិវិធីជួញដូររបស់ផ្សារមូលបត្រកម្ពុជា

# INFORMING KNOWLEDGE RELATED TO TRADING PROCEDURES OF THE CAMBODIAN SECURITIES EXCHANGE

គ្រូណែនាំ៖ តូច សាភ័ណ្ឌា

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**
**ប្រធានបទ៖ការបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនីតិវិធីជួញដូររបស់**
**ផ្សារមូលបត្រកម្ពុជា**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

តូច សាភ័ណ្ឌ

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅសាកលវិទ្យាល័យវ៉ាន់ដាអស់រយៈពេល ៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ដែលពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យ ជាពិសេស ក្រុមយើងខ្ញុំបានយល់ច្បាស់ថាជំនាញគណនេយ្យ គឺជាជំនាញមានសារៈសំខាន់មួយដែរសម្រាប់ ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការគណនេយ្យ ដូចគ្នា។ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិត កាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យវ៉ាន់ដា បាន បញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារគណនេយ្យ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទីមួយ រហូត ដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ពីការអនុវត្ត ការងារធនាគារពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃព្រមទាំងផ្តល់ជា អនុសាសន៍នៅក្នុងការងារធនាគារ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យ បានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញ ថាកិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ បានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី **"ការបញ្ញាបចំណេះដឹងពាក់ព័ន្ធ នីតិវិធីជួញដូររបស់ផ្សារមូលបត្រកម្ពុជា"** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នក ស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការផ្តល់ឥណទានរបស់ ធនាគារ។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិត ជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអាន ទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹង ទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធ



**ផាត សុខឡាង**
ID: B22/210



**សេង ស្រីលីន**
ID: B22/242



**ខួន គឹមល័ង**
ID: B22/233



**ចេង ដាវ**
ID: B22/232



**ឃ្លាំង សុខគាង**
ID: B22/337

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញ គណនេយ្យ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសំដែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្តាលោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវ៉ាន់ដាដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះលោកគ្រូ **តូច សាត់ណ្ណា** ជាគ្រូណែនាំ ដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់លោកគ្រូអ្នកគ្រូ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមនាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យនៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២ សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ "ការបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនីតិវិធីជួញដូររបស់ផ្សារមូលបត្រកម្ពុជា" នេះគឺជាស្នាដៃរបស់ក្រុមនាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃពុធ ៨កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ឆ.ស.២៥៦៩

ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**



ផាត សុខឡាង

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ទីផ្សារមូលបត្រ គឺជាតួអង្គសំខាន់មួយដែលបានចូលរួមចំណែកនៅក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចនៅកម្ពុជានិងធ្វើឱ្យមានលំហូរសាច់ប្រាក់ពីភ្នាក់ងារសេដ្ឋកិច្ចដែលមានមូលធនច្រើនឬនៅសល់ទំនេរទៅឱ្យភ្នាក់ងារ សេដ្ឋកិច្ចដែលមានមូលធនតិចឬខ្វះខាតដើមទុនក្នុងការវិនិយោគអង្គភាពរបស់ខ្លួនទាំងវិស័យឯកជននិង សាធារណៈ ក៏ដូចជាផ្តល់ទុនដល់គម្រោងវិនិយោគថ្មីដែលមានសក្តានុពល និងបង្កើនភាពសម្បូរបែបនៃផលិតកម្ម ទាំងទំនិញនិងសេវាកម្ម។ នៅប្រទេសកម្ពុជាក៏ទើបតែបានដាក់ឱ្យដំណើរការផ្សារមូលបត្ររបស់ខ្លួនជាលើកដំបូងមានឈ្មោះថា ផ្សារមូលបត្រកម្ពុជា ដោយមានការចូលរួមគ្នារវាងរដ្ឋាភិបាល (៥៥%) និងផ្សារមូលបត្រកូរ៉េ(៤៥%)។ ការផ្តល់ទុននេះធ្វើឱ្យកម្រិតសកម្មភាពវិនិយោគនៅក្នុងប្រទេសកើនឡើងជួយបង្កើនដល់ការងារថ្មីជូនប្រជាជនពោលគឺវាផ្តល់ចំណូលបន្ថែមក្នុងការជួយបង្កើនកម្រិតជីវភាព របស់ប្រជាជនបានមួយកម្រិតទៀត។នាពេលបច្ចុប្បន្ននេះទីផ្សារមូលបត្រនៅកម្ពុជាកាន់តែមានភាពសកម្ម និងរីកចម្រើនដោយសារ មានក្រុមហ៊ុនឯកជនគ្រឹះស្ថានសាធារណៈ ធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាច្រើនបានទទួលការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) ដើម្បីធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិនិងមូលបត្រ បំណុល។ បន្ថែមពីនេះក៏មានក្រុមហ៊ុនជាច្រើនទៀតបានសម្តែងនូវឆន្ទៈក្នុងការបោះផ្សាយលក់មូលបត្រនេះផងដែរ។ តួអង្គដ៏សំខាន់មួយទៀតគឺវិនិយោគិនជារូបវន្តបុគ្គលនិងនីតិបុគ្គលដែលទទួលបានលេខអត្តសញ្ញាណវិនិយោគិនពី គ.ម.ក ។ ដោយសម្លឹងឃើញពីសក្តានុពលដ៏ខ្លាំងនេះ គ.ម.ក បានរៀបចំជាព្រឹត្តិបត្រស្តីពីវិនិយោគិន និងការវិនិយោគ និងបោះពុម្ពផ្សាយដើម្បីចែកជូនដល់វិនិយោគិន សាធារណជន ក្រុមហ៊ុនមូលបត្រ គ្រឹះស្ថាន អប់រំ ដៃគូរអភិវឌ្ឍ និងស្ថាប័ននានា ក្នុងគោលដៅចូលរួមចំណែក ផ្តល់នូវចំណេះដឹង និងបទពិសោធន៍បន្ថែម ទៀតពីវិស័យមូលបត្រ។ ផ្សារមូលបត្រកម្ពុជាជាប្រតិបត្តិករទីផ្សារ តែមួយគត់នៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានតួនាទីចម្បងក្នុងការធានានូវតម្លាភាពនិងបង្កើត បរិយាកាសការងារដែលមានភាពល្អប្រសើរខ្លាំងដល់អ្នកចូលរួមនៅក្នុងទីផ្សារ ជាពិសេសនោះគឺក្រុមហ៊ុនក្នុងស្រុកដែលត្រូវការមូលធនសម្រាប់ពង្រីកអាជីវកម្មព្រមជាមួយនឹងការការពារដែលបានផ្តល់ផលប្រយោជន៍របស់វិនិយោគិនជាតិ និងអន្តរជាតិផងដែរ។ លើសពីនេះទៅទៀត មូលបត្រក៏ត្រូវបែងចែកជាពីរគឺ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលដែលត្រូវបានដាក់លក់នៅលើទីផ្សារមូលបត្រ។

# មាតិកា

ទំព័រ


អារម្ភកថា .......... i
រចនាសម្ព័ន្ធក្រុម .......... ii
សេចក្តីថ្លែងអំណរគុណ .......... iii
អំណះអំណាង .......... iv
សេចក្តីសង្ខេបនៃការស្រាវជ្រាវ .......... v
មាតិការ .......... vi


## ជំពូកទី១
## សេចក្តីផ្តើម


១.១ លំនាំបញ្ហានៃការស្រាវជ្រាវ .......... ១
១.២ ចំណោទបញ្ហា .......... ២
១.៣ គោលបំណងនៃការស្រាវជ្រាវ .......... ២
១.៤ ទំហំ វិសាលភាព និង ការស្រាវជ្រាវ .......... ២
  ១.៤.១ ទំហំនិងដែនកំណត់ .......... ២
  ១.៤.២ វិសាលភាព .......... ២
១.៥ វិធីសាស្រ្តនៃការស្រាវជ្រាវ .......... ២
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ .......... ៣
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ .......... ៣


## ជំពូកទី២
## ការបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនីតិវិធីជួញដូររបស់ផ្សារមូលបត្រ


២.១ លក្ខណៈទូទៅនៃនីតិវិធីជួញដូររបស់ផ្សារមូលបត្រ .......... ៥
  ២.១.១ និយមន័យផ្សារមូលបត្រ .......... ៥
  ២.១.២ ប្រវត្តិផ្សារមូលបត្រនានាក្នុងពិភពលោក .......... ៥
  ២.១.៣ ប្រភេទមូលបត្រក្នុងផ្សារមូលបត្រ .......... ៥
២.២. ការយល់ដឹងពីនីតិវិធីនៃការជួញដូរមូលបត្ររបស់ផ្សារមូលបត្រ .......... ៦
  ២.២.១ និយមន័យនីតិ .......... ៦
  ២.២.២ ប្រវត្តិនៃនីតិ .......... ៦
  ២.២.៣ ការចង្អុលបង្ហាញអំពីនីតិ .......... ៧
២.៣ អត្ថប្រយោជន៍នៃការបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនីតិវិធីនៃការជួញដូរមូលបត្ររបស់ផ្សារមូលបត្រដល់សង្គមជាតិ អ្នកវិនិយោគ សាធារណជន .......... ៨
  ២.៣.១ និយមន័យការជួញដូរ .......... ៨

២.៣.២ ប្រវត្តិនៃការជួញដូរ........................................................................................................ ៩
២.៣.៣ ការសិក្សាទៅលើការជួញដូរ.............................................................................................. ១០
ក. មូលបត្រកម្មសិទ្ធិ .................................................................................................................. ១០
ខ. មូលបត្របំណុល...................................................................................................................... ១០

## ជំពូកទី៣
## ការបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនីតិវិធីជួញដូររបស់ផ្សារមូលបត្រកម្ពុជា

៣.១ ស្ថានភាពទូទៅនៃផ្សារមូលបត្រកម្ពុជា.................................................................................... ១១
៣.១.១ ប្រវត្តិរបស់ផ្សារមូលបត្រកម្ពុជា........................................................................................... ១១
៣.១.២ ទីតាំងរបស់ផ្សារមូលបត្រកម្ពុជា .......................................................................................... ១២
៣.១.៣ ចក្ខុវិស័យ និងបេសកម្មរបស់ផ្សារមូលបត្រកម្ពុជា..................................................................... ១២
ក. ចក្ខុវិស័យ ............................................................................................................................ ១២
ខ. បេសកម្ម .............................................................................................................................. ១២
៣.១.៤ រចនាសម្ព័ន្ធរបស់ផ្សារមូលបត្រកម្ពុជា.................................................................................... ១៣
៣.១.៥ ក្រុមប្រឹក្សាភិបាលរបស់ផ្សារមូលបត្រកម្ពុជា ........................................................................... ១៣
៣.២ ការបញ្ជ្រាបចំណេះដឹងរបស់ផ្សារមូលបត្រកម្ពុជាពាក់ព័ន្ធនីតិវិធីនៃការជួញដូរមូលបត្រ................. ១៤
៣.២.១ ការផ្សព្វផ្សាយការជួញដូរមូលបត្រកម្ពុជា ............................................................................... ១៤
ក. សិក្ខាសាលា និងការបណ្តុះបណ្តាល ......................................................................................... ១៤
ខ. បណ្តាញសង្គម........................................................................................................................ ១៥
គ. ការបោះពាណិជ្ជកម្ម (Advertising) ......................................................................................... ១៦
ឃ. ការបោះផ្សាយព័ត៌មានតាមបែបផ្លូវការ...................................................................................... ១៧
៣.២.២ នីតិវិធីនៃការជួញដូរមូលបត្រ ............................................................................................. ១៧
ក. នីតិវិធីក្នុងការបើកគណនី ...................................................................................................... ១៧
ខ. ការដាក់បញ្ជា និងនីតិវិធីក្នុងការជួញដូរ.................................................................................... ១៨
គ. សុពលភាពនៃបញ្ជា ............................................................................................................... ១៩
ឃ.ព័ត៌មានលម្អិតនៃបញ្ជា ........................................................................................................... ១៩
៣.៣ ផលប្រយោជន៍នៃការបញ្ជ្រាបចំណេះដឹងរបស់ផ្សារមូលបត្រកម្ពុជា.................................................. ២០
៣.៣.១ ចំពោះសង្គមជាតិ.................................................................................................................. ២០
៣.៣.២ ចំពោះអ្នកវិនិយោគ ............................................................................................................... ២០
៣.៣.៣ ចំពោះសាធារណជន.............................................................................................................. ២១

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង.......................................................................................................... ២២
៤.២ វិភាគលើចំណុចខ្សោយ............................................................................................................ ២២

## ជំពូកទី៥
## សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

៥.១ សេចក្ដីសន្និដ្ឋាន ........ ២៤
៥.២ ការផ្ដល់អនុសាសន៍ ........ ២៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្ដីផ្ដើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

កម្ពុជា ជាប្រទេសមួយកំពុងអភិវឌ្ឍន៍ ដែលមានទីតាំងស្ថិតនៅភូមិភាគអាស៊ីអាគ្នេយ៍។ សេដ្ឋកិច្ចរបស់កម្ពុជាមួយផ្នែកធំពឹងផ្អែកលើវិស័យគោលចំនួន៣គឺ វិស័យកសិកម្ម សេវាកម្ម និងឧស្សាហកម្ម (ខ្នាតតូចនិងមធ្យម)។ ប៉ុន្តែវិស័យទាំង៣ខាងលើនេះពុំទាន់អាចរុញច្រានសេដ្ឋកិច្ចកម្ពុជាឱ្យឆ្ពោះទៅកាន់គោលដៅដ៏មហិមានៅឡើយទេ។ ក្រៅពីនេះ ការចូលរួមចំណែករបស់ផ្នែករដ្ឋាភិបាល និងឯកជននៅក្នុងវិស័យផ្សេងៗក៏ជាកត្តាលីករយ៉ាងសំខាន់ផងដែរ ដើម្បីជំរុញឱ្យល្បឿននៃកំណើនសេដ្ឋកិច្ចកម្ពុជាមានកម្រិតកាន់តែខ្លាំងក្លាឡើងផងដែរ។ នៅក្នុងនោះយើងសង្កេតឃើញថាការធ្វើឱ្យមានការរីកចម្រើនរបស់ស្ថាប័ននីមួយៗ ទាំងរដ្ឋនិងឯកជន អាចលេចចេញជារូបរាងបាន ក៏អាស្រ័យលើស្ថាប័នទាំងនោះមានប្រព័ន្ធនិងការគ្រប់គ្រងហិរញ្ញវត្ថុដ៏រឹងមាំផងដែរ។ ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុឱ្យបានល្អ ជាពិសេសការធ្វើហិរញ្ញប្បទានសម្រាប់គម្រោងផ្សេងៗរបស់ក្រុមហ៊ុនឬអង្គភាពមួយចំនួនបានប្រើប្រាស់វិធីសាស្ត្រផ្សេងៗពីគ្នាដែលវិធីសាស្ត្រនីមួយៗមានគោលការណ៍ លក្ខខណ្ឌ ផលវិជ្ជមាន និងអវិជ្ជមានដោយឡែកៗពីគ្នា។

ជាការពិតណាស់វិស័យមួយចំនួនត្រូវបានលេចរូបរាងឡើយ ដើម្បីជំរុញក្នុងការអភិវឌ្ឍ សេដ្ឋកិច្ច និងវិស័យនានានៅកម្ពុជាមានការរីកលូតលាស់ឡើង ហើយវិស័យហិរញ្ញវត្ថុ ក៏ជាសរសៃឈាមសម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព។ នៅឆ្នាំ ២០០១ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវ ចក្ខុវិស័យ និងផែនការអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ ២០០១-២០១០ និងត្រូវបានធ្វើបច្ចុប្បន្នភាព ជាបន្តបន្ទាប់ទៅជាយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥ ព្រមទាំងធ្វើការផ្សព្វផ្សាយអំពីផលប្រយោជន៍អំពីវិស័យមូលបត្រដល់សាធារណជន។ ដូចនេះ ដើម្បីធានាថាសាធារណជនទទួលបានព័ត៌មាន និងយល់ដឹងពីនីតិវិធីនៃការជួញដូរមូលបត្រ ចាំបាច់ត្រូវដឹងពីអត្ថប្រយោជន៍ផ្សេងៗការបញ្ជ្រាបចំណេះដឹងផងដែរ។

ជាលទ្ធផល សមិទ្ធផលគួរឱ្យកត់សម្គាល់ក្នុងរយៈពេលកន្លងមក បានលេចជា រូបរាងឡើង រួមមានការពង្រីក និងពង្រឹងប្រព័ន្ធធនាគារ វិស័យធានារ៉ាប់រង និងភតិសន្យាជាដើមៗ ដោយសារតែល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាមានលក្ខណៈខ្លាំងក្លា ការធ្វើទំនើបកម្ម និងការធ្វើសុខដុមនិកម្មនៃវិស័យហិរញ្ញវត្ថុ គឺជាការចាំបាច់ដើម្បីគាំទ្រកំណើន សេដ្ឋកិច្ចនេះ ឱ្យមានចីរភាព។

អាស្រ័យហេតុនេះបានជា វិស័យមូលបត្រ ត្រូវបានបង្កើតឡើងដើម្បីបំពេញ បន្ថែម និងធ្វើឱ្យកាន់តែរឹងមាំនូវសរសៃឈាមនៃប្រព័ន្ធហិរញ្ញវត្ថុកម្ពុជាដែលមានស្រាប់។ ម្យ៉ាងវិញទៀត អត្ថិភាពនៃវិស័យមូលបត្រនេះនឹងធ្វើឱ្យមធ្យោបាយនៃការកៀងគរមូលធន និងការបែងចែកទុនសម្រាប់ផ្តល់ជាហិរញ្ញប្បទានដល់ការវិនិយោគគ្រប់ប្រភេទ ដែលជាចលករនៃកំណើនសេដ្ឋកិច្ចជាតិ។ ដោយសារតែវិស័យនេះជាវិស័យថ្មីមួយសម្រាប់ប្រទេសកម្ពុជា ទើបធ្វើឱ្យវិស័យនេះ ជួបនឹងការលំបាកជាច្រើនពិសេសគឺ ជួបប្រទះនឹងកង្វះខាតខាងផ្នែកធនធានមនុស្ស និងបទពិសោធន៍ដែលជាបញ្ហាចម្បងសម្រាប់ប្រទេសកម្ពុជានៅពេលចាប់ផ្ដើមដំបូង និងកង្វះការយល់ដឹងឱ្យទូលំទូលាយពីសំណាក់ប្រជាពលរដ្ឋ។

## ១.២ ចំណោទបញ្ហា

ការជួញដូរមូលបត្រ គឺមានសារៈសំខាន់ណាស់សម្រាប់សេដ្ឋកិច្ចជាតិព្រោះវាបានចូលរួមចំណែកក្នុងថវិកាជាតិដោយបានប្រមូលពន្ធពីក្រុមហ៊ុនចុះបញ្ជី និងជំរុញឱ្យមានវិនិយោគិននិងជាផ្នែកមួយនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យមានការរីកចម្រើនផងដែរ។ ហេតុដូចនេះទើបក្រុមនាងខ្ញុំមានសំណួរមួយចំនួនមកចោទសួរដូចខាងក្រោម៖

១. តើផ្សារមូលបត្រកម្ពុជាបានបញ្ជ្រាបចំណេះដឹងយ៉ាងដូចម្ដេចខ្លះ ដើម្បីឱ្យប្រជាពលរដ្ឋ ឬវិនិយោគិនយល់ដឹងពីនីតិវិធីនៃការជួញដូរមូលបត្រ?

២. តើការបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនីតិវិធីជួញដូរមូលបត្ររបស់ផ្សារមូលបត្រកម្ពុជាមានអត្ថប្រយោជន៍អ្វីខ្លះ ដល់សង្គមជាតិ អ្នកវិនិយោគ និងសាធារណជន?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវមួយនេះ ធ្វើឡើងក្នុងគោលបំណងដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ពីការជួញដូរមូលបត្រ ដើម្បីស្វែងយល់ឱ្យកាន់តែស៊ីជម្រៅចំពោះលក្ខខណ្ឌរបស់ក្រុមហ៊ុនបន្ថែមឱ្យលើសពីទ្រឹស្តីដែលយើងបានសិក្សាកន្លងមក។ ជារួមក្នុងចំណុចមួយនេះ ក្រុមនាងខ្ញុំមានគោលបំណងចង់បង្ហាញពី ចំណុចសំខាន់ៗដូចខាងក្រោម៖

- យល់ដឹងពីប្រវត្តិផ្សារមូលបត្រ
- យល់ដឹងពីនីតិវិធី នៃការជួញដូរមូលបត្រនៅផ្សារមូលបត្រកម្ពុជា
- យល់ដឹងពីទស្សនៈវិស័យ និងបេសកម្មរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- យល់ដឹងអំពីរបៀបនៃការបញ្ជ្រាបចំណេះដឹងមូលបត្រទៅសាធារណៈជន
- ចំណុចខ្លាំង និងចំណុចខ្សោយរបស់ផ្សារមូលបត្រកម្ពុជា

## ១.៤ ទំហំ វិសាលភាព និង ការស្រាវជ្រាវ

### ១.៤.១ ទំហំនិងដែនកំណត់

នៅក្នុងការជួញដូរមូលបត្រកម្ពុជាមានដំណើរការអស់រយៈពេលជាយូរណាស់មកហើយនៅលើវិស័យមួយនេះដែលមានការចូលរួមពីអ្នកវិនិយោគជាច្រើន។ ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ជាងនេះ ក្រុមយើងខ្ញុំ សូមលើកយកប្រធានបទមួយនិយាយអំពី "ការបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនីតិវិធីជួញដូររបស់ផ្សារមូលបត្រកម្ពុជា"។ ដែលមានអាសយដ្ឋាន អាគារ ផមក, វិថីព្រះមហាក្សត្រីយានី កុសុមៈ (ផ្លូវ. ១០៦), សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា។

### ១.៤.២ វិសាលភាព

ឯកសារយោងនិងការស្រាវជ្រាវមានវិសាលភាពកំណត់ទិន្នន័យត្រឹមឆ្នាំ២០២៥ប៉ុណ្ណោះ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវបានប្រើប្រាស់តាមវិធីសាស្ត្រគុណវិស័យដោយផ្ដោតចម្បងទៅលើការវិភាគទិន្នន័យនិងឯកសារដែលពាក់ព័ន្ធទៅនឹងប្រធានបទ ដើម្បីយកមកវិភាគ និងសិក្សាស្រាវជ្រាវក្នុងគោលបំណងបញ្ជាក់អំពី ការបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនីតិវិធីជួញដូររបស់ផ្សារមូលបត្រកម្ពុជា។

សម្រាប់សំណួរស្រាវជ្រាវទី១៖ ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យដូចជាការវិភាគលើរបាយការណ៍ កម្រងឯកសារនានា វិធីសាស្ត្រស្រាវជ្រាវតាមរយៈគេហទំព័រ បណ្ដាញសង្គមរបស់

ផ្សារមូលបត្រកម្ពុជា ការសិក្សាស្រាវជ្រាវព័ត៌មានខ្លះៗបានមកពីបណ្ណាល័យរបស់សាកលវិទ្យាល័យវ៉ាន់ដា ការដកស្រង់នូវ ឯកសារមេរៀនទាំងឡាយណាដែលពាក់ព័ន្ធនឹងប្រធានបទ ការអានកម្រងឯកសារផ្សេងៗ របាយការណ៍ចាស់ៗ ដែលសិស្សច្បងជំនាន់មុនបានធ្វើរួច និងធ្វើការសាកសួរទៅលោកគ្រូណែនាំបន្ថែម។

សម្រាប់សំណួរស្រាវជ្រាវទី២៖ ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យដូចជា ការវិភាគលើរបាយការណ៍ កម្រងឯកសារនានា វិធីសាស្ត្រស្រាវជ្រាវតាមរយៈគេហទំព័រ បណ្ដាញសង្គមរបស់ផ្សារមូលបត្រកម្ពុជាផ្ទាល់ ការសិក្សាស្រាវជ្រាវព័ត៌មានខ្លះៗបានមកពីបណ្ណាល័យរបស់សាកលវិទ្យាល័យវ៉ាន់ដា ការដកស្រង់នូវ ឯកសារមេរៀនទាំងឡាយណាដែលពាក់ព័ន្ធនឹងប្រធានបទ ការអានកម្រងឯកសារផ្សេងៗ របាយការណ៍ចាស់ៗ ដែលសិស្សច្បងជំនាន់មុនបានធ្វើរួច និងធ្វើការសាកសួរទៅលោកគ្រូណែនាំបន្ថែម។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ពិតជាផ្ដល់សារៈសំខាន់និងអត្ថប្រយោជន៍ជាច្រើន ជាពិសេសចំពោះ៖

### ១.៦.១ ចំពោះក្រុមអ្នកស្រាវជ្រាវផ្ទាល់

- ជួយបង្កើនចំណេះដឹង ជំនាញ សមត្ថភាពផ្ទាល់ខ្លួន ដោយការផ្សារភ្ជាប់រវាងទ្រឹស្ដី និងការអនុវត្តជាក់ស្ដែង
- យល់ដឹងកាន់តែច្បាស់អំពី ការបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធការជួញដូរមូលបត្ររបស់ផ្សារមូលបត្រកម្ពុជា
- យល់ដឹងពីគោលនយោបាយ និងនីតិវិធីរៀបចំផែនការ ការបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធការជួញដូរមូលបត្ររបស់ផ្សារមូលបត្រកម្ពុជា
- ចេះធ្វើការងារជាក្រុម និងចេះសម្របសម្រួលដោះស្រាយបញ្ហាក្នុងក្រុម
- ពង្រឹងបន្ថែមលើកិច្ចការស្រាវជ្រាវ

### ១.៦.២ ចំពោះស្ថាប័ន

- បានដឹងពីចំណុចខ្លាំង និងចំណុចខ្សោយដើម្បីយកមកកែលម្អ និងអភិវឌ្ឍន៍
- បង្កើនទំនុកចិត្តពីសំណាក់អតិថិជន
- ផ្សព្វផ្សាយពីវិសាលភាព និងកេរ្តិ៍ឈ្មោះរបស់ស្ថាប័ន

### ១.៦.៣ ចំពោះសង្គម

- បានផ្សព្វផ្សាយចំណេះដឹងដល់និស្សិតជំនាន់ក្រោយ
- ចងក្រងឯកសារសម្រាប់សិស្សប្អូនធ្វើការស្រាវជ្រាវបន្ត

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវប្រធានបទនេះត្រូវបានបែងចែកចេញជា ៥ ជំពូកធំៗដែលមានលក្ខណៈដូចខាងក្រោម៖

### ជំពូកទី១៖ សេចក្ដីផ្ដើម

នៅក្នុងជំពូកនេះ យើងលើកយកពីការកកើតដំបូងនៃប្រធានបទស្រាវជ្រាវ និងចំណុចមួយចំនួនដែលពាក់ព័ន្ធនឹងដំណើរការស្រាវជ្រាវ ដោយពុំទាន់សិក្សាទៅលើខ្លឹមសារប្រធានបទនៅឡើយទេ។ ជំពូកនេះមាន

បង្ហាញពីលំនាំបញ្ហា ចំណោទបញ្ហា គោលបំណងសំខាន់ ទំហំដែនកំណត់ វិសាលភាព វិធីសាស្ត្រ សារៈសំខាន់ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី២៖ រំលឹកទ្រឹស្តី**

នៅក្នុងជំពូកនេះ យើងនឹងលើកយកពីលក្ខណៈទូទៅដែលពាក់ព័ន្ធនឹងការជួញដូរមូលបត្រ និយមន័យ ប្រភេទ គុណសម្បត្តិ និងគុណវិបត្តិនៃមូលបត្រ ប្រវត្តិ និងអត្ថប្រយោជន៍ដែលទាក់ទងនឹងសំណួរ ក៏ដូចជាទ្រឹស្តីដែលជាប់ពាក់ព័ន្ធយកមកពណ៌នា។

**ជំពូកទី៣៖ លទ្ធផលស្រាវជ្រាវ**

នៅក្នុងជំពូកនេះ ត្រូវលើកយកពីស្ថានភាពទូទៅរបស់អង្គភាព ដូចជាប្រវត្តិរបស់អង្គភាព គោលនយោបាយ ទស្សនៈវិស័យ និងលើកឡើងពាចំណុចទៅលើសកម្មភាពរបស់អង្គភាព។

**ជំពូកទី៤ ៖ ការវិភាគទៅលើចំណុចខ្លាំង និងចំណុចខ្សោយ**

ដែលវិភាគទៅលើគ្រប់ចំណុចទាំងអស់ដែលបង្ហាញពីភស្តុតាងមកបញ្ជាក់ គឺក្នុងគោលបំណងវិភាគនូវចំណុចខ្វះខាតទាំងឡាយដើម្បីធ្វើការកែលម្អ។

**ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍**

នៅក្នុងជំពូកនេះ យើងនឹងយកលទ្ធផលនៃការវិភាគនៅក្នុងជំពូកទី៣ មកទាញការសនិដ្ឋានរួម និងជាចម្លើយរួមរបស់បញ្ហាដែលបានចោទឡើងខាងលើ។ ចំណុចនេះមានបង្ហាញឡើងវិញពីការបកស្រាយនូវចំណុចខ្លាំង និង ចំណុចខ្សោយខាងលើដោយសង្ខេប និងការរកឃើញចំណុចបន្ថែមថ្មីដែលបានមកពីការវិភាគទិន្នន័យ ព្រមទាំងការផ្តល់នូវអនុសាសន៍មួយចំនួនទៅដល់ទីផ្សារមូលបត្រកម្ពុជា និងភាគីពាក់ព័ន្ធដើម្បីជំរុញឱ្យមានភាពប្រសើរឡើង។

# ជំពូកទី២
# ការបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនីតិវិធីជួញដូររបស់ផ្សារមូលបត្រ

## ២.១ លក្ខណៈទូទៅនៃនីតិវិធីជួញដូររបស់ផ្សារមូលបត្រ

### ២.១.១ និយមន័យផ្សារមូលបត្រ

ផ្សារមូលបត្រ (Securities exchange) គឺជាការផ្លាស់ប្តូរមួយដែលឈ្មួញកណ្តាល និងឈ្មួញអាចទិញ និងលក់មូលបត្រ ដូចជាភាគហ៊ុននៃភាគហ៊ុន មូលបត្របំណុល និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត[1]។

### ២.១.២ ប្រវត្តិផ្សារមូលបត្រនានាក្នុងពិភពលោក

ផ្សារមូលបត្រកកើតឡើងចាប់តាំងពីដើមសតវត្សរ៍ទី១៧ នៅគ្រិស្តសករាជ ១៦០២ ទីផ្សារភាគហ៊ុនមានប្រវត្តិកើតឡើងដំបូង នៅលើទឹកដីអឺរ៉ុប នៅទីក្រុងអាំស្ទែដាំ សាធាណរដ្ឋហូឡង់។ នាសតវត្សរ៍ទី១៨ បានរីករាលដាលទៅដល់ប្រទេសព័រទុយហ្គាល់ អេស្ប៉ាញ បារាំង ចក្រភពអង់គ្លេស។ លុះមកដល់គ្រិស្តសករាជ ១៧៧៣ បន្តរីករាលដាលដល់ទីក្រុងឡុងដ៍ ចក្រភពអង់គ្លេស។ ក្រោយមកបានបន្តរីករាលដាលរហូតដល់សហរដ្ឋអាមេរិក នៅគ្រិស្តសករាជ ១៧៩០[2]។



### ២.១.៣ ប្រភេទមូលបត្រក្នុងផ្សារមូលបត្រ

នៅក្នុងផ្សារមូលបត្រមានការទិញលក់មូលបត្រមានចំនួន ២ប្រភេទគឺ មូលបត្រកម្មសិទ្ធ (Equity Securities) និង មូលបត្របំណុល (Debt Securities)។ មូលបត្រកម្មសិទ្ធ ផ្តល់ភាពជាម្ចាស់កម្មសិទ្ធម្នាក់ដល់អ្នកវិនិយោគ ក្នុងការទទួលបានចំណែកនៃប្រាក់ចំណេញ និងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនដែលខ្លួនបានទិញមូលបត្រទៅតាមចំណែកនៃមូលបត្រសរុបដែលខ្លួនបានទិញ។ រីឯការទិញមូលបត្របំណុល មានន័យថាអ្នកវិនិយោគក្លាយ

[1] Wikipedia. (2025, July 10). *What is Securities Exchange?* Retrieved from https://en.wikipedia.org/wiki/Stock_exchange

[2] វិទ្យាស្ថានវ៉ាន់ដា. (ឆ្នាំ២០២៣). *ទស្សនាវដ្តីវិទ្យាសាស្ត្រ.* បោះពុម្ពលើកទី២. ទំព័រទី៤៦. ៨១ទំព័រ. ភ្នំពេញ។

ជាម្ចាស់បំណុលម្នាក់ នៃក្រុមហ៊ុនដែលខ្លួនបានទិញមូលបត្រ ដោយទទួលបាន ប្រាក់ចំណេញតាមរយៈការប្រាក់នៅគ្រាកំណត់មួយ(ប្រចាំខែ ឬប្រចាំឆ្នាំ) ហើយទទួលបានប្រាក់ដើមមកវិញនៅចុងគ្រា[3]។

## ២.២ ការយល់ដឹងពីនីតិវិធីនៃការជួញដូរមូលបត្ររបស់ផ្សារមូលបត្រ

### ២.២.១ និយមន័យនីតិ

នីតិ គឺជាវិធានទាំងឡាយដែលគ្រប់គ្រងជីវភាពរស់នៅក្នុងសង្គម ដោយមានការដាក់ទណ្ឌកម្មពីអំណាចសាធារណៈ[4]។

នីតិ គឺជាៈ

- ជាវិធានគ្រប់គ្រងឥរិយាបថសង្គមមនុស្សផ្លូវការ។
- ជាក្បួន ឬជាវិន័យប្រដៅមនុស្សឱ្យប្រព្រឹត្តល្អ។
- ជាឧបករណ៍ដើម្បីការពារ និងអភិវឌ្ឍន៍តម្លៃនៃសង្គមមនុស្ស។
- ជាអត្ថបទដែលបញ្ញត្តិអំពីវិធានគតិយុត្តិដោយអង្គការនីតិបញ្ញត្តិ (រដ្ឋសភា និងព្រឹទ្ធសភា) និង ត្រូវប្រកាសឱ្យប្រើតាមរយៈព្រះរាជក្រមដែលឡាយព្រះហស្តលេខាដោយប្រមុខរដ្ឋ[5]។

នីតិ(Law/droit) គឺជាវិទ្យាសាស្ត្រច្បាប់ សិក្សាលើសំណុំវិធានទាំងឡាយណា ដែលមនុស្សជាអ្នកបង្កើតឡើង ដើម្បីគ្រប់គ្រងការរស់នៅ និងគ្រប់គ្រងការទំនាក់ទំនងរបស់មនុស្សក្នុងសង្គមតាមរយៈការអនុវត្ត និងផ្តន្ទាទោសដាក់ទណ្ឌកម្ម ដោយអំណាចសាធារណៈ។ លើសពីនេះទៅទៀត នីតិជាមធ្យោបាយដោះស្រាយទំនាស់ក្នុងសង្គម[6]។

### ២.២.២ ប្រវត្តិនៃនីតិ

នៅសម័យសង្គមបុព្វកាលមនុស្សរស់នៅដោយគ្មានច្បាប់អ្វីទេ ប៉ុន្តែមនុស្សអាចរស់នៅជាមួយគ្នាបានហើយថែមទាំងមានការគោរពគ្នាទៅវិញទៅមកទៀតផង។ ការរស់នៅរបៀបនេះ គឺជាការរស់នៅតាមរយៈការគោរពនូវទំនៀមទម្លាប់ប្រពៃណី និងសាសនាជាដើម។ ប៉ុន្តែក្នុងពេលខ្លះក៏មានការរំលោភបំពាន ការធ្វើបាប ការជិះជាន់ ការកេងប្រវ័ញ្ច និងការជំទាស់ប្រឆាំងគ្នាជានិរន្តរ៍ផងដែរ។ទង្វើបែបនេះធ្វើឱ្យ មនុស្សយល់ថា គួរតែរៀបចំឱ្យមាននូវឆន្ទៈរួមមួយ។ ឆន្ទៈរួមនេះធ្វើឱ្យការរស់នៅរបស់មនុស្សតាមទម្លាប់ ខាងលើមានការវិវត្តន៍ទៅជាការរៀបចំនូវក្បួនខ្នាតមួយចំនួន ដើម្បីជាការរក្សាទុកក៏ដូចជាការបន្តការគោរពនូវទំនៀមទម្លាប់ប្រពៃណីខាងលើនាពេលក្រោយៗទៀត។

ភស្តុតាងជាក់ស្តែងជាច្រើនបានបង្ហាញឱ្យយើងឃើញថា ច្បាប់បានចាប់កកើតឡើងតាំងពីយូរយារណាស់មកហើយ ពោលគឺតាំងពីសម័យដើមមកម្ល៉េះ គឺតាំងពីសម័យកាលដែលមនុស្សចេះរួបរួមគ្នា រស់នៅជាក្រុម ជាពួក ជាកុលសម្ព័ន្ធ ដោយត្រូវមានក្រុមមេពួក ឬមេកន្ទ្រាញ (ស្តេចត្រាញ់)។ មេក្រុម មេពួក មេកន្ទ្រាញ តែងតែរិះរកគំនិត និងវិធានផ្សេងៗ ដើម្បីធ្វើការគ្រប់គ្រងកូនចៅរបស់ខ្លួន។ ការគ្រប់គ្រងនេះហើយដែលជាការចាប់ផ្តើមកកើតនូវច្បាប់មួយដែលមេក្រុម មេពួក ឬមេកន្ទ្រាញខ្លះគ្រប់គ្រងតាមបែប ផ្តាច់ការ និងខ្លះមិន

[3] កាក់សេន-Kakcent. (2020, September 23). *តើមូលបត្រចែកចេញជាប៉ុន្មាន ?* Retrieved from https://www.facebook.com/kakcentkh/posts

[4] វិទ្យាស្ថានវ៉ាន់ដា. (ឆ្នាំ២០២២). *សេចក្តីផ្តើមនៃនីតិ.* បោះពុម្ពលើកទី៩. ទំព័រទី៤. ១០១ទំព័រ. ភ្នំពេញ។

[5] វិទ្យាស្ថានវ៉ាន់ដា. (ឆ្នាំ២០២២). *សេចក្តីផ្តើមនៃនីតិ.* បោះពុម្ពលើកទី៩. ទំព័រទី៤. ១០១ទំព័រ. ភ្នំពេញ។

[6] វិទ្យាស្ថានវ៉ាន់ដា. (ឆ្នាំ២០២២). *សេចក្តីផ្តើមនៃនីតិ.* បោះពុម្ពលើកទី៩. ទំព័រទី៣. ១០១ទំព័រ. ភ្នំពេញ។

ផ្តាច់ការ។ រហូតដល់មានជាការគ្រប់គ្រងដោយព្រះរាជា ដែលព្រះរាជាធ្វើការគ្រប់គ្រងនគរ ការពារអំណាច ការពារតំណែង និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជារាស្រ្តបាន។ ទាំងនេះគឺជាការបញ្ជាក់អំពីភាពរីកចម្រើននៃកំណើតរបស់ច្បាប់។

យ៉ាងណាមិញនៅប្រទេសកម្ពុជា យើងអាចប្រមើលឃើញថា តើមានការលំបាកយ៉ាងណាខ្លះក្នុងបេសកកម្មកសាងប្រាសាទអង្គរវត្ត។ ជាការពិតណាស់ក្នុងដំណើរការនៃការកសាងនេះ គឺពិតជាមានការ លំបាកយ៉ាងខ្លាំង ទាំងបច្ចេកទេស ធនធាន និងការគ្រប់គ្រងពិសេសគឺការសាងសង់។ ដើម្បីដោះស្រាយ បញ្ហាទាំងនេះគឺត្រូវទាមទារឱ្យមាននូវច្បាប់នៃការគ្រប់គ្រងសង្គមមួយដ៏មានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ ដូចនេះ យើងអាចនិយាយជារួមបានថា ច្បាប់គឺពិតជាមានតាំងពីយូរយារណាស់មកហើយ គ្រាន់ តែយើងមិនមានឯកសារបញ្ជាក់ច្បាស់លាស់តែប៉ុណ្ណោះ ប៉ុន្តែយើងអាចមើលទៅលើភស្តុតាងមួយចំនួន ដែលបន្សល់ទុកដូចជាប្រាសាទអង្គរវត្ត មហាកំពែងចិន...[7]។

**២.២.៣ ការទទួលបន្ទាញអំពីនីតិ**

មតិរបស់អ្នកច្បាប់ មិនមែនជាប្រភពនៃនីតិដែលមានអានុភាពដាច់ខាតទេ។ ក៏ប៉ុន្តែទ្រឹស្តីនេះ បានដើរតួនាទីយ៉ាងសំខាន់ខាងវិស័យនីតិ។ ទ្រឹស្តីមានន័យពីរយ៉ាងសំខាន់គឺ៖

- ក្នុងន័យទូលាយ គឺជាបណ្តាគំនិតយោបល់របស់អ្នកច្បាប់
- ក្នុងន័យចង្អៀត គឺជាបណ្តាគំនិតយោបល់ទាំងឡាយលើបញ្ហាគតិយុត្តិណាមួយជាកំណត់។ ទ្រឹស្តី ជាភ្នាក់ងារនៃការបកស្រាយស្ទាត់កំបាំងនៃវិជ្ជានីតិ និង យុត្តិសាស្រ្ត។

យុត្តិសាស្រ្ត មិនអាចចាប់បានដោយអ្នកមិនចេះអក្សរបានទេ។ ដោយនាំឱ្យងាយយល់សេចក្តីសម្រេចរបស់តុលាការសំខាន់ៗបំផុតនោះដោយធ្វើឱ្យគេបានស្គាល់នូវសេចក្តីសម្រេចទាំងនេះដោយទ្រឹស្តីអនុញ្ញាតឱ្យបុគ្គលនិងរដ្ឋាភិបាលយកសេចក្តីសម្រេចរបស់តុលាការមកសំអាងជាច្បាប់។

ទ្រឹស្តីបញ្ចូលភាពស៊ីសង្វាក់គ្នាក្នុងសេចក្តីសម្រេចជាបន្តបន្ទាប់គ្នាដែលនៅរាយប៉ាយ។ ទង្វើនេះវាបង្ហាញឱ្យឃើញមិនត្រឹមតែគំនិតលាក់បាំងរបស់ចៅក្រមប៉ុណ្ណោះទេ ក៏ប៉ុន្តែវាក៏បង្ហាញនូវអ្វីៗដែលចៅក្រមបានសម្រេចដែលប្រកបដោយមនសិការទៀតផង។ គេអាចនិយាយថាស្នាដៃទ្រឹស្តីជាច្រើនផ្អែកលើសេចក្តីសម្រេចរបស់តុលាការ។

ទ្រឹស្តី បង្ហាញផងដែរការឱ្យតម្លៃរិះគន់លើអត្ថបទ និងសេចក្តីសម្រេចរបស់តុលាការ។ វារួមចំណែកចំពោះការផ្លាស់ប្តូរច្បាប់ បទបញ្ញា ឬ យុត្តិសាស្រ្ត រួមចំណែកចំពោះការរីកចម្រើននៃច្បាប់[8]។

---

[7] វិទ្យាស្ថានវ៉ាន់ដា. (ឆ្នាំ២០២២). *សេចក្តីផ្តើមនៃនីតិ.* បោះពុម្ពលើកទី៩. ទំព័រទី២ដល់៣. ១០១ទំព័រ. ភ្នំពេញ។

[8] រៀបរៀងដោយនិស្សិតឈ្មោះ ម៉ាលីន ភីនតារាពេជ្រ, ឃាង សូរិយ៉ា, ឃឿម កន្និកា, ខេន ស្រីនាថ. (២០២១). ប្រធានបទ៖ *ការជួញដូរមូលបត្រនៅកម្ពុជា.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យ ជំនាន់ទី១៩ នៃវិទ្យាស្ថានវ៉ាន់ដា. ទំព័រទី៤ ៣៨ទំព័រ. រាជធានីភ្នំពេញ។

## ២.៣ អត្ថប្រយោជន៍នៃការបញ្ច្រាបចំណេះដឹងពាក់ព័ន្ធនីតិវិធីនៃការជួញដូរមូលបត្រ របស់ផ្សារមូលបត្រដល់សង្គមជាតិ អ្នកវិនិយោគ សាធារណជន

### ២.៣.១ និយមន័យការជួញដូរ

ការជួញដូរ គឺជាសកម្មភាពនៃការទិញ និងលក់ទំនិញ ឬសេវាកម្ម[9]។

ការជួញដូរ គឺជាគំនិតសេដ្ឋកិច្ចមូលដ្ឋានពាក់ព័ន្ធនឹងការទិញនិងលក់ទំនិញ ឬសេវាកម្មដោយមានការទូទាត់សងដោយអ្នកទិញទៅអ្នកលក់ ឬការដោះដូរទំនិញ ឬសេវាកម្មរវាងភាគី[10]។

ការជួញដូរ គឺជាការផ្តល់របស់មួយជាថ្នូរនឹងរបស់មួយផ្សេងទៀត[11]។

ការជួញដូរ គឺជាយុទ្ធសាស្ត្រវិនិយោគរយៈពេលខ្លីនៅក្នុងការវិនិយោគផ្សារហ៊ុន[12]។

ការជួញដូរមានន័យថា ការទិញ និងលក់ភាគហ៊ុន រូបិយប័ណ្ណ សញ្ញាបណ្ណ ទំនិញ និងមូលបត្រហិរញ្ញវត្ថុផ្សេងទៀតក្នុងរយៈពេលខ្លីដើម្បីទទួលបានប្រាក់ចំណេញ[13]។

ការជួញដូរគឺជាការផ្លាស់ប្តូរទំនិញ និងសេវាកម្មរវាងភាគីនានាក្នុងគោលបំណងផ្តល់ផលប្រយោជន៍ទៅវិញទៅមក[14]។

ការជួញដូរ គឺជាការទិញ-លក់ឧបករណ៍ហិរញ្ញវត្ថុ ដើម្បីរកប្រាក់ចំណេញ។ ឧបករណ៍ទាំងនេះមានចាប់ពីទ្រព្យសកម្មជាច្រើនដែលត្រូវបានកំណត់តម្លៃហិរញ្ញវត្ថុដែលអាចឡើង ឬចុះហើយអ្នកអាចជួញដូរតាមទិសដៅដែលពួកគេនឹងធ្វើ[15]។




[9] ម៉ាលីន គីនតារាពេជ្រ, យាង សូរិយ៉ា, ឃឿម កន្និកា, ខេន ស្រីនាថ. (២០២១). ប្រធានបទ៖ *ការជួញដូរមូលបត្រនៅកម្ពុជា*. សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ ជំនាន់ទី១៩. វិទ្យាស្ថាន វ៉ាន់ដា. រាជធានីភ្នំពេញ.ទំព័រទី១០ ៣៤ទំព័រ. ភ្នំពេញ។

[10] ម៉ាលីន គីនតារាពេជ្រ, យាង សូរិយ៉ា, ឃឿម កន្និកា, ខេន ស្រីនាថ. (២០២១). ប្រធានបទ៖ *ការជួញដូរមូលបត្រនៅកម្ពុជា*. សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ ជំនាន់ទី១៩. វិទ្យាស្ថាន វ៉ាន់ដា. រាជធានីភ្នំពេញ.ទំព័រទី១០ ៣៤ទំព័រ. ភ្នំពេញ។

[11] ម៉ាលីន គីនតារាពេជ្រ, យាង សូរិយ៉ា, ឃឿម កន្និកា, ខេន ស្រីនាថ .(២០២១). ប្រធានបទ៖ ការជួញដូរមូលបត្រនៅកម្ពុជា. សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ ជំនាន់ទី១៩. វិទ្យាស្ថាន វ៉ាន់ដា. រាជធានីភ្នំពេញ.ទំព័រទី១០ ៣៤ទំព័រ. ភ្នំពេញ។

[12] ម៉ាលីន គីនតារាពេជ្រ, យាង សូរិយ៉ា, ឃឿម កន្និកា, ខេន ស្រីនាថ .(២០២១). ប្រធានបទ៖ ការជួញដូរមូលបត្រនៅកម្ពុជា. សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ ជំនាន់ទី១៩. វិទ្យាស្ថាន វ៉ាន់ដា. រាជធានីភ្នំពេញ.ទំព័រទី១០ ៣៤ទំព័រ. ភ្នំពេញ។

[13] Bajaj Finserv. (2025, June, 13). *What is Trading?* Retrieved from https://share.google/kbMLd0ATKiZRWnrGb

[14] Investopedia. (2024, May, 31). *What is Trading?* Retrieved from https://share.google/shFKMj9DUnSzQPeqc

[15] IG. (2021). *What is Trading?* Retrieved from https://share.google/xnsxlcIxQDquyJl9D

### ២.៣.២ ប្រវត្តិនៃការជួញដូរ

ការជួញដូរមានប្រភពចេញពីទំនាក់ទំនងរបស់មនុស្សនៅសម័យបុរេប្រវត្តិ។ ការធ្វើការជួញដូរគឺជាកន្លែងសំខាន់នៃប្រជាជននៅសម័យបុរេប្រវត្តិដែលបានផ្លាស់ប្តូរទំនិញនិងសេវាកម្មពីគ្នាទៅវិញទៅមក នៅក្នុងសេដ្ឋកិច្ចអំណោយផលមួយមុនពេលការកែច្នៃប្រឌិតរូបិយបណ្ណ។ ការជួញដូរមានប្រវត្តិតាំងពី១៥០,០០០ឆ្នាំមុនម្ល៉េះ។ គេជឿថាការជួញដូរត្រូវបានធ្វើឡើងដោយរាប់ចំនួនបរិមាណនៃប្រវត្តិសាស្ត្ររបស់មនុស្ស។ ភស្តុតាង នៃការផ្លាស់ប្តូរ Obsidian និង Flint ក្នុងយុគសម័យថ្មី។ ការធ្វើការជួញដូរនៅក្នុងការឃ្លាំមើលត្រូវបានគេជឿ ថាបានធ្វើឡើងនូវ New Guinea ពីឆ្នាំ១៧,០០០ មុនគ.ស។

ការវិវត្តនៃការជួញដូរគឺជាកត្តាសំខាន់បំផុតមួយនៅក្នុងដំណើររបស់មនុស្សលោក។ មនុស្សជាតិបានវិវត្តពេញមួយសតវត្សហើយនោះមិនអាចទៅរួចទេប្រសិនបើពួកគេត្រូវបានដាក់កម្រិតលើភូមិសាស្ត្រ។ ការធ្វើការជួញដូរគឺជាប្រព័ន្ធនៃការនាំមនុស្សរួមគ្នា ដើម្បីទទួលបាននូវផលប្រយោជន៍ទៅវិញទៅមកបើទោះបីជាសង្គមបុព្វកាលបានឃើញនូវការប្រមូលផ្តុំមនុស្សតែនៅក្នុងព្រឹត្តិការណ៍សាសនា និងវប្បធម៌ដែលត្រូវបានកំណត់ ដោយទំនៀមទម្លាប់ ឬក្រុមគ្រួសារ[16]។



[16] ម៉ាលីន ភឺនតារាពេជ្រ, យាង សូរិយ៉ា, ឃឿម កន្នីកា, ខេន ស្រីនាថ. (២០២១). ប្រធានបទ៖ *ការជួញដូរមូលបត្រនៅកម្ពុជា*. សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ. វិទ្យាស្ថាន វ៉ាន់ដា. រាជធានីភ្នំពេញ.ទំព័រទី១០ ៣៤ទំព័រ. ភ្នំពេញ។

### ២.៣.៣ ការសិក្សានៅលើការជួញដូរ

ទ្រឹស្តីនៃបរិមាណជួញដូរ ត្រូវបានបង្កើតឡើងដោយផ្អែកឡើងលើការសន្មតថាភ្នាក់ងារក្នុងការពិនិត្យមើលតម្រូវការរបស់ខ្លួនជាញឹកញាប់ ហើយជួបដោយចែដន្យជាមួយដៃគូរពាណិជ្ជកម្មដែលមានសក្តានុពល។ គំរូពិពណ៌នាអំពីវិធីពីរយ៉ាងខុសគ្នាដែលមានឥទ្ធិពលលើទំហំពាណិជ្ជកម្មមួយគឺស្របទៅនឹងការអះអាងដែលធ្វើឡើងដោយអ្នកស្រាវជ្រាវអាឡឺម៉ង់ដែលយល់ថាការមិនយល់ស្របរបស់វិនិយោគិននាំឱ្យមានការកើនឡើងទៅលើពាណិជ្ជកម្ម។ ប៉ុន្តែការសង្កេតលើបរិមាណជួញដូរមិនធម្មតាមិនចាំបាច់បង្ហាញពីការខ្វែងគំនិតគ្នាទេ ហើយបរិមាណអាចកើនឡើង ទោះបីជាវិនិយោគិនបកស្រាយព័ត៌មានដោយអត្តសញ្ញាណក៏ដោយប្រសិនបើ ពួកគេមានការរំពឹងទុកខុសគ្នាដែរ។ ការធ្វើត្រាប់តាមការពិសោធគាំទ្រដល់គំរូហើយត្រូវបានប្រើដើម្បីប្រៀបធៀបបរិយាកាសផ្គូរផ្គងដោយចៃដន្យជាមួយការទូទាត់ទីផ្សារដែលមិនថ្លៃ។ បរិមាណ គឺទាបជាងថ្លៃនៅក្នុងទីផ្សារ ហើយបរិមាណកើនឡើងបណ្តាលមកពីព្រឹត្តិការណ៍ព័ត៌មាននៅតែបន្តបន្ទាប់ពីព្រឹត្តិការណ៍នេះ។ ស្របទៅតាមភស្តុតាងដែលមានស្រាប់ និងបង្ហាញថាទីផ្សារមិនត្រូវបានបញ្ជាទិញភ្លាមៗ ឬវិនិយោគិនមានការទាមទារដើម្បីដកហូតបានមកវិញទេ។

បច្ចុប្បន្ន មានការជួញដូរមួយប្រភេទដែលកំពុងតែមានសន្ទុះនោះគឺ ការជួញដូរមូលបត្រ។ ក្នុងនោះ គេបែងចែកមូលបត្រជា២ប្រភេទមូលបត្រកម្មសិទ្ធ ( Equity Securities ) មូលបត្របំណុល (Debt Securities)[17]។

#### ក. មូលបត្រកម្មសិទ្ធិ

មូលបត្រកម្មសិទ្ធ បើនិយាយឱ្យខ្លី គឺវាតំណាងឱ្យភាពជាម្ចាស់ទ្រព្យ។ នៅពេលដែលក្រុមហ៊ុនមួយដល់ដំណាក់កាលត្រូវពង្រីកខ្លួនឬត្រូវការទុនបន្ថែមដើម្បីប្រើប្រាស់ក្នុងគម្រោងថ្មី នោះពួកគេនឹងធ្វើការសិក្សាអំពីលទ្ធភាពក្នុងការបោះផ្សាយមូលបត្រកម្មសិទ្ធិ ដើម្បីលក់ទៅឱ្យសាធារណៈជនក្នុងគោលដៅយកប្រាក់ ដែលបានពីអតិថិជនមកប្រើប្រាស់។ នៅពេលដែលក្រុមហ៊ុនកំណត់ចំនួនហ៊ុនដែលត្រូវបោះលក់ហើយនោះ ពួកគេនឹងយកហ៊ុនទៅដាក់លក់ក្នុងទីផ្សារហ៊ុន ឬទីផ្សារបើកចំហ[18]។

#### ខ. មូលបត្របំណុល

មូលបត្របំណុលបើនិយាយឱ្យខ្លីគឺវាតំណាងឱ្យភាពជាម្ចាស់បំណុល។ វាហាក់បីដូចជារឿងមួយដែលផ្សេងពីភាគហ៊ុន (Stock) បន្តិច ដោយហេតុថាមួយបង្ហាញពីភាពជាម្ចាស់ទ្រព្យហើយមួយទៀតបង្ហាញពីភាពជាម្ចាស់បំណុល។ នៅពេលដែលក្រុមហ៊ុនត្រូវការប្រាក់បន្ទាន់ត្រូវបង្វិលឬដើម្បីបំពេញលំហូរសាច់ប្រាក់ដែលខ្វះខាតនោះពួកគេនឹងសម្រេចចិត្តបោះផ្សាយបណ្ណបំណុលដើម្បីលក់។ លក្ខណៈនៃការបោះផ្សាយបណ្ណបំណុលនេះ គឺធ្វើឡើងដើម្បីប្រមូលទុនដូចគ្នា ប៉ុន្តែវាមានការកំណត់ និងផ្តល់អត្រាការប្រាក់ទៅឱ្យអ្នកដែល បានទិញបណ្ណបំណុលនោះ។ វាប្រៀបដូចជាយើងខ្ចីប្រាក់ពីធនាគារយើងត្រូវឱ្យអត្រាការប្រាក់រៀងរាល់ខែ ឬ ត្រីមាស[19]។

---

[17] ម៉ាលីន ភីនតារាពេជ្រ, យ៉ាង សូរិយ៉ា, ឃឿម កន្និកា, ខេន ស្រីនាថ .(២០២១). ប្រធានបទ៖ *ការជួញដូរមូលបត្រនៅកម្ពុជា*. សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ. វិទ្យាស្ថាន វ៉ាន់ដា. រាជធានីភ្នំពេញ.ទំព័រទី១០ដល់ទី១១ ៣៨ទំព័រ. ភ្នំពេញ។

[18] ម៉ាលីន ភីនតារាពេជ្រ, យ៉ាង សូរិយ៉ា, ឃឿម កន្និកា, ខេន ស្រីនាថ.(២០២១). ប្រធានបទ៖ *ការជួញដូរមូលបត្រនៅកម្ពុជា*. សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ. វិទ្យាស្ថាន វ៉ាន់ដា. រាជធានីភ្នំពេញ.ទំព័រទី១១ ៣៨ទំព័រ. ភ្នំពេញ។

[19] ម៉ាលីន ភីនតារាពេជ្រ, យ៉ាង សូរិយ៉ា, ឃឿម កន្និកា, ខេន ស្រីនាថ. (២០២១). ប្រធានបទ៖ ការជួញដូរមូលបត្រនៅកម្ពុជា. សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ. វិទ្យាស្ថាន វ៉ាន់ដា. រាជធានីភ្នំពេញ.ទំព័រទី១១ ៣៨ទំព័រ. ភ្នំពេញ។

# ជំពូកទី៣
# ការបញ្ច្រាបចំណេះដឹងពាក់ព័ន្ធនីតិវិធីជួញដូរបស់ផ្សារមូលបត្រកម្ពុជា

## ៣.១ ស្ថានភាពទូទៅនៃផ្សារមូលបត្រកម្ពុជា

### ៣.១.១ ប្រវត្តិរបស់ផ្សារមូលបត្រកម្ពុជា

ដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រទេសកម្ពុជា ដោយឈរលើគោលដៅក្នុងការជំរុញកំណើនសេដ្ឋកិច្ច តាមរយៈលំហូរមូលធន ការវិនិយោគ និង ការវិភាជន៍ជាថ្មីនូវមូលធនតាមយន្តការទីផ្សារមូលធន នៅខែ វិច្ឆិកា ឆ្នាំ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្តីអំពី "ការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា"។ដោយផ្អែកលើអនុស្សរណៈយោគយល់នេះ សម្តេចអគ្គសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសបើកឱ្យដំណើរការគម្រោងបង្កើតទីផ្សារមូលបត្រនៅប្រទេសកម្ពុជា នៅខែកញ្ញា ឆ្នាំ ២០០៧។ នៅឆ្នាំ ២០០៨ អនុស្សរណៈយោគយល់មួយទៀតស្តីអំពី "ការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា" ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុន ផ្សារមូលបត្រកូរ៉េ។ នៅខែ មីនា ឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ បានចុះកិច្ចព្រមព្រៀង ក្រុមហ៊ុនចំរុះ (Joint Venture) ដើម្បីបង្កើតផ្សារមូលបត្រ "ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា" ស្របតាមច្បាប់ស្តីអំពីសហគ្រាសសាធារណៈ។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានចុះក្នុងបញ្ជីពាណិជ្ជកម្មនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០។ ស្របតាមកិច្ចព្រមព្រៀង ក្រុមហ៊ុនចំរុះ (Joint Venture) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកាន់កាប់ភាគហ៊ុនចំនួន ៥៥% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ហើយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េកាន់កាប់ភាគហ៊ុនចំនួន៤៥% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានទទួលអាជ្ញាបណ្ណ ជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រ ពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ស្របតាមច្បាប់ស្តីអំពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។



### ៣.១.២ ទីតាំងរបស់ផ្សារមូលបត្រកម្ពុជា

បច្ចុប្បន្នផ្សារមូលបត្រកម្ពុជាមានអាសយដ្ឋាននៅ អាគារ ផមក, វិថីព្រះមហាក្សត្រីយានី កុសុមៈ (ផ្លូវ. ១០៦), សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា។




### ៣.១.៣ ចក្ខុវិស័យ និងបេសកកម្មរបស់ផ្សារមូលបត្រកម្ពុជា

#### ក. ចក្ខុវិស័យ

ដើម្បីធ្វើឱ្យក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា មានដំណើរការល្អនិងការរីកចម្រើន នៅលើមាគ៌ាមួយដ៏ត្រឹមត្រូវ ក្រុមហ៊ុនបានកំណត់គោលការណ៍យ៉ាងច្បាស់លាស់ ទៅលើចក្ខុវិស័យរបស់ខ្លួនគឺ ដើម្បីកសាងនូវ "មហាវិថី" ហិរញ្ញវត្ថុសម្រាប់កម្ពុជា ក្នុងគោលបំណងផ្តល់ភាពងាយស្រួលដល់ អតិថិជនក្នុងការជួញដូរមូលបត្រ។

#### ខ. បេសកកម្ម

បេសកកម្មរបស់ផ្សារមូលបត្រកម្ពុជាគឺ

- ដើម្បីសម្រួលក្នុងការកៀរគរមូលធនរបស់ក្រុមហ៊ុននៅកម្ពុជា
- ដើម្បីបង្កើតនូវបរិយាកាសជួញដូរមូលបត្រដែលអំណោយផលដល់អ្នកវិនិយោគិនទាំងក្នុងនិងក្រៅប្រទេស
- ដើម្បីបង្កើតនូវផលិតផលនិងសេវាកម្មដ៏ទំនើបជាច្រើនប្រភេទសម្រាប់ អ្នកចូលរួមទីផ្សារទាំងអស់
- ដើម្បីដាក់ឱ្យដំណើរការនូវសហគ្រាសសាធារណៈមួយដែលមានស្វ័យចិរភាពក្រោមមគ្គុទេសក៏ដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា

### ៣.១.៤ រចនាសម្ព័ន្ធរបស់ផ្សារមូលបត្រកម្ពុជា

រចនាសម្ព័ន្ធគ្រប់គ្រងរបស់ផ្សារមូលបត្រកម្ពុជា




### ៣.១.៥ ក្រុមប្រឹក្សាភិបាលរបស់ផ្សារមូលបត្រកម្ពុជា

♦ ក្រុមប្រឹក្សាភិបាលនៃ ផ.ម.ក រួមមានសមាជិកចំនួន ៧រូប ដោយរាប់បញ្ចូលទាំងប្រធានក្រុមប្រឹក្សាភិបាល អនុប្រធានក្រុមប្រឹក្សាភិបាល (ដែលជាអគ្គនាយករងផងដែរ) និងអគ្គនាយក។ ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកជាតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជា។ ចំណែកឯអនុប្រធានក្រុមប្រឹក្សាភិបាលគឺជាតំណាងរបស់ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។

♦ សមាជិកចំនួន ៤រូបផ្សេងទៀតគឺជាអភិបាលមិនអចិន្ត្រៃយ៍ ដោយក្នុងនោះ២រូបត្រូវបានតែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង២រូបទៀតត្រូវបានតែងតាំងដោយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។
ព័ត៌មានស្ដីពីសមាជិកក្រុមប្រឹក្សាភិបាល

1. **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** (ប្រធានក្រុមប្រឹក្សាភិបាល)
   រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
2. **Mr. BAE HEUNGSOO** (អនុប្រធានក្រុមប្រឹក្សាភិបាល)
   អគ្គនាយករងនៃផ្សារមូលបត្រកម្ពុជា
3. **ឯកឧត្តម ហុង សុហួរ** (សមាជិក)
4. **ឯកឧត្តម អ៊ូ ចាន់តារា** (សមាជិក)
   អគ្គលេខាធិការនៃធនាគារជាតិនៃកម្ពុជា
5. **ឯកឧត្តម ហ៊ឹម ហ៊ាន** (សមាជិក)
   ទីប្រឹក្សាក្រសួងពាណិជ្ជកម្ម
6. **Mr. JI HYUNGUN** (សមាជិក)
7. **Mr.SHIN BYUNG MOOK** (សមាជិក)

## ៣.២ ការបញ្ច្រាបចំណេះដឹងរបស់ផ្សារមូលបត្រកម្ពុជាពាក់ព័ន្ធនីតិវិធីនៃការជួញដូរមូលបត្រ

### ៣.២.១ ការផ្សព្វផ្សាយការជួញដូរមូលបត្រកម្ពុជា

និយ័តករមូលបត្រកម្ពុជាហៅកាត់ថា ន.ម.ក. មានគោលដៅគ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គមតាមរយៈការកៀគរមូលធនពីសាធារណជន ឬអ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅកម្ពុជា។ ព្រមទាំងដើម្បីកសាងនូវ "មហាវិថី" ហិរញ្ញវត្ថុសម្រាប់កម្ពុជា និយ័តករមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជាមានវិធីសាស្ត្របញ្ជ្រាបការយល់ដឹងពាក់ព័ន្ធនីតិវិធីជួញដូរមូលបត្រ ទៅដល់សាធារណជនតាមវិធីដូចខាងក្រោម៖

#### ក. សិក្ខាសាលា និងការបណ្តុះបណ្តាល

- សិក្ខាសាលា ស្តីពី "ហិរញ្ញវត្ថុនិរន្តភាព និងផែនទីបង្ហាញផ្លូវសម្រាប់វិនិយោគិន" (04/03/2025)
- សិក្ខាសាលា ស្តីពី "ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធនៃការបង្ហាញព័ត៌មានសាជីវកម្មដំណាក់កាលទី១" (05/03/2025)
- សិក្ខាសាលា ស្តីពី "កំណាប់ក្នុងផ្សារមូលបត្រ" (20/03/2025)
- សិក្ខាសាលា ស្តីពី "គន្លឹះក្នុងការសរសេរព័ត៌មាន និងការផ្សព្វផ្សាយឱ្យចំគោលដៅក្នុងសម័យឌីជីថល" (01/04/2025)
- សិក្ខាសាលា ស្តីពី "ការពង្រឹងអនុលោមភាពតាមច្បាប់របស់ក្រុមហ៊ុនអន្តរការីមូលបត្រ" (23/04/2025)
- វគ្គបណ្តុះបណ្តាល ស្តីពី "កម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យមូលបត្រលើកទី២៩" (09/05/2025)
- វេទិកាវិនិយោគិនលើកទី១ ស្តីពី "ការសន្សំមូលបត្រ" (09/05/2025)
- សិក្ខាសាលា ស្តីពី "សេចក្តីព្រាងផែនការមេសម្រាប់ការអភិវឌ្ឍវិស័យមូលបត្រ ឆ្នាំ២០២៥ - ២០៣៥" (12/05/2025)
- វគ្គបណ្តុះបណ្តាល ស្តីពី "ការវិនិយោគឆ្លាតវៃ" (24/05/2025)
- សិក្ខាសាលា ស្តីពី "វិស័យមូលបត្រនៅកម្ពុជា" (03-04/06/2025)
- សិក្ខាសាលា ស្តីពី "ការស្វែងយល់អំពីឧបករណ៍វិនិយោគ និងហិរញ្ញប្បទានក្នុងវិស័យមូលបត្រ" (17/06/2025)
- សិក្ខាសាលា ស្តីពី "ការគាំពារវិនិយោគិន និងការពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យមូលបត្រ" (24/06/2025)
- សិក្ខាសាលា ស្តីពី "ការបំប្លែងភាពស្មុគស្មាញទៅជាឱកាស៖ ដំណើរឆ្ពោះទៅកាន់ទីផ្សារមូលធនប្រកបដោយទំនុកចិត្តរបស់ក្រុមហ៊ុនហូលឌីង" (30/06/2025)
- សិក្ខាសាលា ស្តីពី "ការគាំពារវិនិយោគិន និងការពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យមូលបត្រ" (26/02/2024)
- សិក្ខាសាលា ស្តីពី "វិស័យមូលបត្រនៅកម្ពុជា" (26/01/2024)






## ខ. បណ្តាញសង្គម

1. បណ្តាញសង្គម (Social Media)
   - ផ្សព្វផ្សាយមូលបត្រតាម Facebook, Twitter, YouTube, LinkedIn ដើម្បីបង្ហាញព័ត៌មានថ្មីៗ។
   - ផ្សព្វផ្សាយវីដេអូពន្យល់អំពីមូលបត្រ និងរបៀបវិនិយោគ។
2. កម្មវិធីផ្ញើសារ (Messaging Apps)
   - ផ្ញើមូលបត្រតាម Telegram Channel, Telegram Bot, Messenger Group, WhatsApp...

3. អ៊ីមែល (Email Marketing)
   - ផ្ញើមូលបត្រដល់អតិថិជនដែលបានចុះឈ្មោះ
4. គេហទំព័រ (Website/Popup/Blog)
   - បង្ហាញ Popup/មុខងារ “Subscribe and get a discount” ដើម្បីផ្តល់ Voucher
   - បង្ហោះព័ត៌មានលម្អិតក្នុង Landing Page ឬ Blog
5. ក្នុងផ្សារមូលបត្រកម្ពុជាផ្ទាល់ (ផ.ម.ក.)
   - បែងចែកជាសន្លឹក ឬ QR Code នៅច្រកចូល ឬជាប់នឹងផលិតផល
   - ផ្តល់មូលបត្រជាមួយវិក័យបត្រ (Receipt)







## គ. ការបោះពាណិជ្ជកម្ម (Advertising)

1. ដាក់ពាណិជ្ជកម្មតាមទូរទស្សន៍, វិទ្យុ, ទស្សនាវដ្ដី និងសារព័ត៌មានអេឡិចត្រូនិក។
2. ប្រើបដាផ្សព្វផ្សាយ និងអេក្រង់ LED នៅតំបន់សាធារណៈ។

### ឃ. ការបោះផ្សាយព័ត៌មានតាមបែបផ្លូវការ

1. រៀបចំសន្និសីទសារព័ត៌មានពេលមានការចូល IPO ថ្មី ឬព្រឹត្តិការណ៍សំខាន់។




### ៣.២.២ នីតិវិធីនៃការជួញដូរមូលបត្រ

#### ក. នីតិវិធីក្នុងការបើកគណនី

**ជំហ៊ានទី១ ជ្រើសរើសក្រុមហ៊ុនមូលបត្រ**

វិនិយោគិនត្រូវជ្រើសរើសក្រុមហ៊ុនមូលបត្រមួយក្នុងចំណោមក្រុមហ៊ុនមូលបត្រទាំង១០ដែលជាសមាជិករបស់ ផ.ម.ក ហើយក្រុមហ៊ុនមូលបត្រនោះនឹងជួយវិនិយោគិនក្នុងការបើកគណនីជួញដូរ។

**ជំហ៊ានទី២ បើកគណនីជួញដូរ**

ឯកសារតម្រូវដើម្បីបើកគណនីជួញដូររួមមានៈ

១. អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន( សម្រាប់ជនបរទេស ) ភ្ជាប់ជាមួយរូបថត ៤x៦ មួយសន្លឹក

២. លេខអត្តសញ្ញាណវិនិយោគិន (ក្រុមហ៊ុនមូលបត្រអាចជួយធ្វើការស្នើសុំពីគណៈកម្មការមូលបត្រកម្ពុជា )

**ជំហ៊ានទី៣ ការដាក់បញ្ជា**

❖ .វិនិយោគិនបង្គាប់ឱ្យក្រុមហ៊ុនមូលបត្ររបស់ខ្លួនដាក់បញ្ជាមកកាន់ ផ.ម.ក ដោយបញ្ជាក់ប្រាប់យ៉ាងហោចនូវព័ត៌មានសំខាន់ៗដូចខាងក្រោមៈ

១-ឈ្មោះមូលបត្រ

២-បរិមាណ

៣-ថ្លៃ

៤-ប្រភេទនៃបញ្ជាទិញ ឬបញ្ជាលក់

❖...វិនិយោគិនអាចបង្គាប់ទៅក្រុមហ៊ុនមូលបត្រឱ្យដាក់បញ្ជាដោយប្រើប្រាស់មធ្យោបាយទំនាក់ទំនងណាមួយខាងក្រោម៖

១-ឯកសារជាលាយលក្ខណ៍អក្សរ

២-ពាក្យសំដី

៣-សារអេឡិចត្រូនិក

៤-មធ្យោបាយអេឡិចត្រូនិកដទៃទៀត

តើវិនិយោគិនអាចចាប់ផ្តើមជួញដូរបាននៅពេលណា? យ៉ាងហោចណាស់មួយថ្ងៃបន្ទាប់ពីបើកគណនីជួញដូររួច ទើបវិនិយោគិនអាចដាក់បញ្ជាទៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក បាន។

## ខ. ការដាក់បញ្ជា និងនីតិវិធីក្នុងការជួញដូរ

វិនិយោគិនអាចដាក់បញ្ជាបានលុះត្រាតែមានសាច់ប្រាក់យ៉ាងហោចមួយរយភាគរយ (សម្រាប់បញ្ជាទិញ) ដែលរួមបញ្ចូលទាំងថ្លៃសេវាឈ្មួញជើងសារមូលបត្រ ឬបរិមាណមូលបត្រយ៉ាងហោចមួយរយភាគរយ (សម្រាប់បញ្ជាលក់)។ ពេលបញ្ជាត្រូវបានបញ្ជូនចេញ សាច់ប្រាក់និងមូលបត្រទាំងនេះនឹងត្រូវបានបង្កកទុកដោយសមាជិក ក្នុងគោលបំណងដើម្បីទូទាត់ ឬបង្កកទុករហូតដល់ពេលបញ្ជានោះអស់ សុពលភាព។




(១) វិនិយោគិនបើកគណនីជួញដូរ (គណនីមូលបត្រ និងគណនីសាច់ប្រាក់) នៅក្រុមហ៊ុនមូលបត្រនៅថ្ងៃ T-1។ ក្រុមហ៊ុនមូលបត្រនឹងធ្វើការស្នើសុំលេខអត្តសញ្ញាណវិនិយោគិនជូនអតិថិជនរបស់ខ្លួនពីគណៈកម្មការមូលបត្រកម្ពុជា។

(២) វិនិយោគិនដាក់បញ្ជាទិញ ឬលក់នៅថ្ងៃ T+0 តាមប្រព័ន្ធជួញដូរចល័ត (MTS) ឬក្រុមហ៊ុនមូលបត្រជាលាយលក្ខណ៍អក្សរ ជាពាក្យសម្ដី (ត្រូវបានថតទុកដោយអ្នកតំណាងនៅក្នុងទីផ្សារ) ឬមធ្យោបាយអេឡិចត្រូនិចនានា។

(៣) បន្ទាប់ពីដាក់បញ្ជាមកក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. នៅថ្ងៃ T+0 បានជោគជ័យដោយមានមូលបត្រ និងសាច់ប្រាក់គ្រប់គ្រាន់ នៅក្នុងគណនីរបស់វិនិយោគិន (សាច់ប្រាក់ ឬបរិមាណមូលបត្រមួយរយភាគរយដែលពាក់ព័ន្ធនឹងបញ្ជានោះ) សាច់ប្រាក់ ឬមូលបត្រនឹងត្រូវបានបង្កកទុកសម្រាប់ទូទាត់នៅថ្ងៃ T+2។

(៤) ការបញ្ជាទាំងឡាយត្រូវបានផ្គូរផ្គងនៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. ទៅតាមគោលការណ៍ដេញថ្លៃដែលបានកំណត់ទុកជាមុន។

(៥) ផ.ម.ក. ជូនដំណឹងអំពីលទ្ធផលនៃការជួញដូរ នៅថ្ងៃ T+0។

(៦) ក្រុមហ៊ុនមូលបត្របញ្ជាក់លទ្ធផលនៃការជួញដូរដែលពាក់ព័ន្ធជាមួយអតិថិជននីមួយៗរបស់ខ្លួននៅថ្ងៃT+0។

(៧) ក្នុងករណីមានកំហុសឆ្គងដែលបង្កឡើងដោយក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនមូលបត្រនោះត្រូវដាក់ពាក្យស្នើសុំមកកាន់ ផ.ម.ក. ដើម្បីកែតម្រូវឱ្យបានមុនពេលថ្ងៃត្រង់នៃថ្ងៃ T+1។ បន្ទាប់ពីកំហុសឆ្គងត្រូវបានកែតម្រូវហើយ ដំណើរការក្នុងចំណុចទី៥ និងទី៦ នឹងត្រូវអនុវត្តម្ដងទៀត។

(៨) វិនិយោគិនបង់ប្រាក់ ឬបញ្ជូនមូលបត្រតាមរយៈក្រុមហ៊ុនមូលបត្រនៅថ្ងៃ T+2។

(៩) ក្រុមហ៊ុនមូលបត្រទូទាត់ការជួញដូរក្នុងនាមជាវិនិយោគិននៅ ផ.ម.ក. ។

### គ. សុពលភាពនៃបញ្ជា

បញ្ជានីមួយៗមានសុពលភាពចាប់ពីពេលដែលទទួលបាននៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. រហូតដល់ពេលដែលបញ្ជានោះត្រូវបានអនុវត្តនៅអំឡុងវគ្គជួញដូរនៃថ្ងៃតែមួយ។

### ឃ.ព័ត៌មានលម្អិតនៃបញ្ជា

បញ្ជាដែលដាក់ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក ត្រូវមានព័ត៌មានលម្អិតនីមួយៗដូចខាងក្រោម៖

១-ឈ្មោះមូលបត្រ

២-បរិមាណ

៣-ថ្លៃ

៤-ប្រភេទនៃបញ្ជា បញ្ជាទិញ ឬបញ្ជាលក់

៥-ប្រភេទនៃប្រតិបត្តិការ (ប្រតិបត្តិការគណនីអតិថិជន ឬប្រតិបត្តិការគណនីសមាជិក)

៦-លេខអត្តសញ្ញាណសមាជិក

៧-លេខអត្តសញ្ញាណវិនិយោគិន

៨-លេខបញ្ជា

៩-លេខគណនី

១០-ក្នុងករណីបញ្ហាត្រូវបានលុប ឬកែប្រែត្រូវបញ្ជាក់លើបញ្ហានោះថា ជាការលុប ឬ ជាការកែប្រែហើយត្រូវបញ្ជាក់ពីលេខបញ្ហាដើមផងដែរ

១១-លេខកូដចំណាត់ថ្នាក់វិនិយោគ

១២-លេខកូដសញ្ជាតិ និងលេខកូដចំណាត់ថ្នាក់វិនិយោគិនចំពោះវិនិយោគិនបរទេស។

## ៣.៣ ផលប្រយោជន៍នៃការបញ្ជ្រាបចំណេះដឹងរបស់ផ្សារមូលបត្រកម្ពុជា

អត្ថប្រយោជន៍នៃការបញ្ជ្រាបចំណេះដឹងរបស់ផ្សារមូលបត្រកម្ពុជាទៅកាន់ សង្គមជាតិ អ្នកវិនិយោគ និងសាធារណជន មានដូចខាងក្រោម៖

### ៣.៣.១ ចំពោះសង្គមជាតិ

- លើកកម្ពស់វប្បធម៌ហិរញ្ញវត្ថុ៖ ការចេះពីបច្ចេកទេសវិនិយោគធ្វើឱ្យសង្គមមានការយល់ដឹងអំពីវិធីគ្រប់គ្រងទ្រព្យសម្បត្តិ។
- ជម្រុញការអភិវឌ្ឍសេដ្ឋកិច្ច៖ បើសង្គមយល់ដឹងច្រើន នឹងមានការចូលរួមវិនិយោគច្រើន ជម្រុញឱ្យសហគ្រាស និងប្រទេសមានប្រាក់ចំណូលចូលប្រព័ន្ធធនាគារ។
- ធ្វើឱ្យសង្គមមានជំនាញសម្រេចចិត្តលើបញ្ហា ហិរញ្ញវត្ថុយ៉ាងប្រក្រតី។
- អភិវឌ្ឍសេដ្ឋកិច្ចជាតិនិងទីផ្សារហិរញ្ញវត្ថុ ការយល់ដឹងល្អអំពីនីតិវិធីនឹងជម្រុញឱ្យមានការវិនិយោគបន្ថែម។
- ជួយអភិវឌ្ឍបរិស្ថានទីផ្សារឱ្យមានប្រសិទ្ធភាព និងសុវត្ថិភាព។
- បង្កើតសង្គមមួយដែលមានចំណេះដឹងហិរញ្ញវត្ថុខ្ពស់ ជួយឱ្យប្រជាជនយល់អំពីនីតិវិធីនៃការវិនិយោគ និងជួញដូរមូលបត្រ។ បង្កើនសមត្ថភាពក្នុងការប្រមូលប្រាក់ វិនិយោគ និងគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន។
- ជំរុញការរីកចម្រើនសេដ្ឋកិច្ចសង្គម ជួយបង្កើតបរិយាកាសវិនិយោគឱ្យច្រើនជាងមុន។
- បង្កើនការសហការរវាងសាធារណជន និងរដ្ឋក្នុងការគ្រប់គ្រងផ្សារមូលបត្រ។ បង្កើនប្រសិទ្ធភាពនៃវិធានការរដ្ឋ និងភាពជឿជាក់លើប្រព័ន្ធហិរញ្ញវត្ថុជាតិ។

### ៣.៣.២ ចំពោះអ្នកវិនិយោគ

- ទទួលបានព័ត៌មានត្រឹមត្រូវ៖ ដោយការផ្តល់ចំណេះដឹង អ្នកវិនិយោគអាចយល់ពីហានិភ័យ ការវិភាគសេដ្ឋកិច្ច និងអនុវត្តការវិនិយោគបានត្រឹមត្រូវ។
- បង្កើនការចូលរួម៖ មានការយល់ដឹងនិងមានទំនុកចិត្តក្នុងទីផ្សារមូលបត្រយូរជាងមុន។
- យល់ដឹងអំពីការជួញដូរនិងវិនិយោគមូលបត្របានត្រឹមត្រូវ
- ជួយអ្នកវិនិយោគធ្វើការសម្រេចចិត្តយ៉ាងឆ្លាតវៃ អ្នកវិនិយោគដែលយល់ច្បាស់អំពីនីតិវិធីអាចវាយតម្លៃហានិភ័យ និងជ្រើសរើសការវិនិយោគបានសមរម្យ។
- បង្កើនភាពជាក់ច្បាស់នៃការវិនិយោគ និងការគ្រប់គ្រងទុន។
- បន្ថយហានិភ័យនៃការចូលរួមក្នុងអំពើមិនស្របច្បាប់ ដូចជា insider trading ឬការលួចបន្លំផ្សារ។ បង្កើនការជឿជាក់ក្នុងទីផ្សារហិរញ្ញវត្ថុ អ្នកវិនិយោគដែលមានចំណេះដឹងនឹងមានទំនុកចិត្តក្នុងប្រព័ន្ធច្បាប់ និងគ្រប់គ្រងទីផ្សារ។ ជម្រុញឱ្យមានការវិនិយោគយ៉ាងសកម្ម និងយូរអង្វែង។

- បង្កើតសមត្ថភាពក្នុងការស្វែងរកឱកាសថ្មី ជួយអ្នកវិនិយោគយល់អំពីផលិតផលហិរញ្ញវត្ថុថ្មីៗ និងច្បាប់ពាក់ព័ន្ធ។ មានសមត្ថភាពបញ្ចៀសឱកាសវិនិយោគខុសច្បាប់ ឬខ្ពស់ហានិភ័យ។
- ជម្រុញភាពទាក់ទាញនៃទីផ្សារដល់វិនិយោគិនអន្តរជាតិ ប្រសិនបើអ្នកវិនិយោគក្នុងស្រុកមានចំណេះដឹងល្អ នឹងបង្កើតភាពជឿជាក់ដល់វិនិយោគិនក្រៅប្រទេស។ ជួយលើកកម្ពស់ភាពប្រកួតប្រជែងនៃទីផ្សារជាតិ។

**៣.៣.៣ ចំពោះសាធារណជន**

- ឱកាសចូលរួមក្នុងទីផ្សារហិរញ្ញវត្ថុៈសាធារណជនអាចវិនិយោគបន្ទាប់ពីយល់ដឹងពីផលិតផលហិរញ្ញវត្ថុ។
- លើកស្ទួយសេដ្ឋកិច្ចគ្រួសារៈបង្កើនចំណូល
- សាធារណជនអាចសម្គាល់ក្រុមហ៊ុនបន្លំ និងបញ្ហាខុសច្បាប់បាន។
- បង្កើនការយល់ដឹង និងការចូលរួមរបស់សាធារណជន បណ្តុះបណ្តាលឱ្យប្រជាពលរដ្ឋយល់ច្បាស់អំពីនីតិវិធីជួញដូរមូលបត្រ។ ជម្រុញឱ្យមានការចូលរួមផ្ទាល់ក្នុងផ្សារមូលបត្រ ដូចជាការវិនិយោគ និងទិញលក់មូលបត្រ។
- បង្កើនភាពស្របច្បាប់ និងភាពជឿជាក់ ជួយស្តារឡើងវិញនូវភាពជឿជាក់លើប្រព័ន្ធហិរញ្ញវត្ថុ។
- ជំរុញឱ្យមានការចូលរួមយ៉ាងស្មើភាពក្នុងផ្សារមូលបត្រ ដោយគ្មានការរើសអើង។
- បង្កើនភាពច្បាស់លាស់ និងការត្រួតពិនិត្យ ជួយសាធារណជនយល់ពីវិធានការទប់ស្កាត់ការលួចបន្លំ និងអំពើមិនស្របច្បាប់។ ជួយក្រុមប្រឹក្សាគ្រប់គ្រងផ្សារធ្វើការត្រួតពិនិត្យយ៉ាងមានប្រសិទ្ធភាព។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ក្នុងនាមក្រុមនាងខ្ញុំជានិស្សិតសរសេរសារណាបញ្ចប់ការសិក្សាដែលសរសេរស្តីពី "ការបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនីតិវិធីជួញដូររបស់ផ្សារមូលបត្រកម្ពុជា" បានមើលឃើញថាទីផ្សារមូលបត្រគឺជាមូលដ្ឋានមួយយ៉ាងសំខាន់សម្រាប់សេដ្ឋកិច្ចជាតិ គេតែងនិយាយថាទីផ្សារមូលបត្រនេះគឺជានិមិត្តរូបមួយនៃសេដ្ឋកិច្ចជាតិមួយទៀត។ ហេតុដូចនេះហើយទើបមានចំណុចខ្លាំង និងចំណុចខ្សោយដូចខាងក្រោម៖

## ៤.១ ការវិភាគលើចំណុចខ្លាំង

- បង្កើនការយល់ដឹង៖ សាធារណៈជនអាចយល់ពីឱកាសនិងហានិភ័យនៃការវិនិយោគបានកាន់តែច្បាស់។
- ការអប់រំហិរញ្ញវត្ថុ៖ ជួយអភិវឌ្ឍចំណេះដឹងហិរញ្ញវត្ថុរបស់ប្រជាពលរដ្ឋ និងបង្កើនសមត្ថភាពក្នុងការគ្រប់គ្រងសម្បទានិម្មិត។
- ការចូលរួមប្រកបដោយទំនួលខុសត្រូវ៖ ជម្រុញឱ្យប្រជាពលរដ្ឋចូលរួមក្នុងទីផ្សារហិរញ្ញវត្ថុយ៉ាងសកម្ម និងផ្អែកលើព័ត៌មានត្រឹមត្រូវ។
- បង្កើតសេដ្ឋកិច្ចមានស្ថេរភាព៖ ការយល់ដឹងល្អអំពីនីតិវិធីជួញដូរមូលបត្រជួយសម្រួលឱ្យប្រព័ន្ធហិរញ្ញវត្ថុមានស្ថេរភាព និងទំនុកចិត្ត។
- ជំរុញការរីកចម្រើនផ្នែកហិរញ្ញវត្ថុ៖ បង្កើនការចូលរួមរបស់ប្រជាជនទៅកាន់ទីផ្សារហិរញ្ញវត្ថុ ដែលជាជំហានសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។
- ជួយធ្វើការសម្រេចចិត្តល្អប្រសើរ៖ អ្នកវិនិយោគអាចវាយតម្លៃហានិភ័យ និងឱកាសក្នុងទីផ្សារដោយផ្អែកលើចំណេះដឹងត្រឹមត្រូវ។
- ការការពារទឹកប្រាក់វិនិយោគ៖ ជួយកាត់បន្ថយការបាត់បង់ដោយសារការបន្លំ ឬការជួញដូរមិនត្រឹមត្រូវ។
- បង្កើនទំនុកចិត្តក្នុងទីផ្សារ៖ ធ្វើឱ្យអ្នកវិនិយោគមានទំនុកចិត្តលើប្រព័ន្ធ និងបន្តវិនិយោគក្នុងរយៈពេលវែង។

## ៤.២ វិភាគលើចំណុចខ្សោយ

- ការយល់ច្រឡំ៖ ប្រសិនបើព័ត៌មានដែលផ្តល់មិនច្បាស់លាស់ ឬមិនត្រឹមត្រូវ អាចនាំឱ្យសាធារណជនយល់ខុសអំពីទីផ្សារមូលបត្រ និងនាំទៅរកការជួញដូរខុសៗ។
- ជម្រើសវិនិយោគដោយគ្មានសមត្ថភាព៖ អ្នកខ្វះបទពិសោធន៍អាចធ្វើការវិនិយោគដោយគ្មានការវិភាគល្អ ធ្វើឱ្យប្រឈមនឹងហានិភ័យខ្ពស់។
- ការលើកទឹកចិត្តលើការវិនិយោគខ្លាំងហួសហេតុ៖ ការផ្សព្វផ្សាយខ្លាំងអំពីការវិនិយោគអាចធ្វើឱ្យប្រជាជនយល់ថាវាជាវិធីរកចំណូលឆាប់រហ័ស ដោយមិនយកចិត្តទុកដាក់ទៅលើការបង្ការនូវហានិភ័យផ្សេងៗ។
- ការបង្កើតបរិយាកាសឧក្រិដ្ឋភាពហិរញ្ញវត្ថុ៖ ប្រសិនបើការបញ្ជ្រាបមិនបានគ្រប់គ្រងល្អ អាចនាំឱ្យមានការកើនឡើងនៃសកម្មភាពលួចលាក់ ឬការបន្លំមូលបត្រ។
- ការបន្ថយទំនុកចិត្តសង្គម៖ ប្រសិនបើមានករណីបរាជ័យក្នុងការវិនិយោគជាច្រើន វាអាចបណ្តាលឱ្យសង្គមបាត់បង់ទំនុកចិត្តលើប្រព័ន្ធហិរញ្ញវត្ថុ។

- ការសង្ស័យចំពោះព័ត៌មាន៖ អ្នកវិនិយោគខ្លះអាចមិនទុកចិត្តលើព័ត៌មាន ដែលផ្តល់តាមសាធារណៈ ប្រសិនបើខ្វះប្រភពសម្រេចចិត្តឬគ្រប់គ្រងល្អ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវទាក់ទងទៅនឹងផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) រួចមក យើងខ្ញុំទទួលបាននូវចំណេះដឹងជាច្រើនដែលទាក់ទងទៅនឹងវិស័យមូលបត្រ។ ផ្សារមូលបត្រកម្ពុជា ជាប្រតិបត្តិករទីផ្សារតែមួយគត់នៅព្រះរាជាណាចក្រកម្ពុជា ហើយមានតួនាទីយ៉ាងសំខាន់ក្នុងប្រតិបត្តិការទីផ្សារក្នុងការធានានូវតម្លាភាព និងដើរតួយ៉ាងសំខាន់ ក្នុងការបង្កើតបរិយាកាសដល់អ្នកចូលរួមនៅក្នុងទីផ្សារ ជាពិសេសជួយជំរុញនិងលើកទឹកចិត្តដល់សហគ្រិន វិនិយោគិន តាមរយៈការធ្វើឱ្យមាននូវសន្ទនីយភាពទីផ្សារនិងការពារផលប្រយោជន៍ដល់វិនិយោគិននៅក្នុងទីផ្សារផងដែរ។ បច្ចុប្បន្ននេះ យើងសង្កេតឃើញថាវិស័យមូលបត្រនៅកម្ពុជាបាននឹងកំពុងអភិវឌ្ឍន៍ទៅមុខគួរឱ្យកត់សម្គាល់។

តាមរយៈនៃការសិក្សាស្រាវជ្រាវលើប្រធានបទ ការបញ្រ្ជាបចំណេះដឹងពាក់ព័ន្ធនីតិវិធីជួញដូររបស់ផ្សារមូលបត្រកម្ពុជាខាងលើកន្លងមក យើងសង្កេតឃើញថា វិស័យមូលបត្រជាផ្នែកមួយដែលបានជួយដល់វិស័យហិរញ្ញវត្ថុក៏ដូចជាជួយជម្រុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជាផងដែរ។ជាក់ស្តែងវិនិយោគិន និងសាធារណជនបានស្គាល់ពីមូលបត្រកាន់តែច្រើនតាមរយៈផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) និងនិយ័តករមូលបត្រកម្ពុជា (ន.ម.ក.) បានព្យាយាមក្នុងការផ្សព្វផ្សាយការជួញដូរមូលបត្រតាមរយៈ បណ្តាញសង្គម ការធ្វើបទសម្ភាសន៍ និងវគ្គបណ្តុះបណ្តាលសិក្ខាសាលាផ្សេងៗជាដើម។ លើសពីនេះទៅទៀត ការយល់ដឹងពីការជួញដូរមូលបត្រនៅកម្ពុជាក៏អាចជាចំណែកមួយដែលជួយឱ្យមាន ស្ថេរភាពហិរញ្ញវត្ថុ ការវិនិយោគឆ្លាតវៃ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិផងដែរ។

សរុបសេចក្តីមកការសិក្សាស្រាវជ្រាវកន្លងមកទៅលើការបញ្រ្ជាបចំណេះដឹងពាក់ព័ន្ធនីតិវិធីជួញដូររបស់ផ្សារមូលបត្រកម្ពុជា យើងសង្កេតឃើញថាវិស័យមូលបត្រនៅកម្ពុជានឹងមានសន្ទុះនៃការគាំទ្រកាន់តែខ្លាំងពីសំណាក់វិនិយោគិនធំៗក៏ដូចជាប្រជាពលរដ្ឋដែលមានបំណងចង់ធ្វើការជួញដូរមូលបត្រ។ ដោយយើង គ្រប់គ្នាបានដឹងហើយថាការជួញដូរទៅលើមូលបត្រទទួលបានទាំងប្រាក់ចំណេញនិងភាគលាភប្រចាំឆ្នាំដូច្នេះយើងចូលរួមលើកស្ទួយ សេដ្ឋកិច្ចជាតិយើងឱ្យកាន់តែរីកចម្រើនតាមរយៈការទិញ លក់មូលបត្រដូចនៅបណ្តាប្រទេសដែលអភិវឌ្ឍន៍។

## ៥.២ ការផ្តល់អនុសាសន៍

ទោះបីជាទីផ្សារមូលបត្រកើតមានការជួញដូរមកអស់ពេលជាយូរក៏ដោយក៏នៅតែមានចំណុចខ្វះខាត មួយចំនួនផងដែរ អាស្រ័យហេតុនេះហើយដើម្បីឱ្យមានការរីកចម្រើន ព្រមទាំងទទួលបានជោគជ័យ ក្រុមយើង ខ្ញុំសូមធ្វើការផ្តល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

- ផ្សារមូលបត្រកម្ពុជា គួរតែពង្រីកការផ្សព្វផ្សាយវិស័យមូលបត្រឱ្យកាន់តែទូលំទូលាយជាងមុនតាមរយៈ ប្រព័ន្ធអ៊ិនធើណេត ទូរទស្សន៍ និងតាមបណ្តាញព័ត៌មានផ្សេងៗទៅកាន់ប្រជាពលរដ្ឋ ដើម្បីជំរុញឱ្យការ ជួញដូរមូលបត្រមានភាពរីកចម្រើនកាន់តែខ្លាំង

- ស្វែងរកមធ្យោបាយ ឬវិធីសាស្រ្តថ្មីៗបន្ថែមដើម្បីឱ្យការជួញដូរកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ
- រាល់អ្នកវិនិយោគទាំងអស់ត្រូវតែស្វែងយល់ពីវិស័យមួយនេះ ឱ្យកាន់តែច្បាស់សិនមុន និងធ្វើការបណ្តាក់ទុននៅក្នុងការជួញដូរ
- ត្រូវបង្កើនសេចក្តីទុកចិត្តពីវិនិយោគិនទាំងឡាយ ដែល ផ.ម.ក ត្រូវតែពន្យល់បន្ថែមពីការជួញដូរ និងការពិភាក្សាពីបញ្ហាផ្សេងៗ ដើម្បីឱ្យអ្នកវិនិយោគមានភាពជឿជាក់
- ផ្សារមូលបត្រកម្ពុជាគួរតែទៅសិក្សាស្វែងយល់នៅចំណុចផ្សេងៗពីបណ្តាប្រទេសជិតខាង ដើម្បីយកមកអភិវឌ្ឍន៍បន្ថែមទៀត

# ឯកសារយោង

➢ ឯកសារសៀវភៅ


១. វិទ្យាស្ថានវ៉ាន់ដា. (ឆ្នាំ២០១៨). *វិស័យមូលបត្រនៅកម្ពុជា.* បោះពុម្ពលើកទី២.១៤១ទំព័រ.ភ្នំពេញ។

២. វិទ្យាស្ថានវ៉ាន់ដា. (ឆ្នាំ២០២៣) *ទស្សនាវដ្ដីវិទ្យាសាស្ត្រ.* បោះពុម្ពលើកទី២. ៨១ទំព័រ. ភ្នំពេញ។

៣. វិទ្យាស្ថានវ៉ាន់ដា. (ឆ្នាំ២០២២). *សេចក្ដីផ្ដើមនៃនីតិ.* បោះពុម្ពលើកទី៩. ទំព័រទី៤. ១០១ទំព័រ. ភ្នំពេញ។

៤. រៀបរៀងដោយនិស្សិតឈ្មោះ ម៉ាលីន ភីនតាពពេជ្រ, ឃាង សូរិយ៉ា, ឃឿម កន្និកា, ខេន ស្រីនាថ. (២០២១). ប្រធានបទ៖*ការជួញដូរមូលបត្រនៅកម្ពុជា.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យ ជំនាន់ទី១៩ នៃ វិទ្យាស្ថានវ៉ាន់ដា. ទំព័រទី៤ ៣៤ទំព័រ. រាជធានីភ្នំពេញ។

៥. វិទ្យាស្ថានវ៉ាន់ដា. (ឆ្នាំ២០២៣). *ទស្សនាវដ្ដីវិទ្យាសាស្ត្រ.* បោះពុម្ពលើកទី២. ទំព័រទី៤៦. ៨១ទំព័រ. ភ្នំពេញ។


➢ គេហទំព័រ


៦. Wikipedia. (2025, July 10). *What is Securities Exchange?* Retrieved from https://en.wikipedia.org/wiki/Stock_exchange

៧. កាក់សេន-Kakcent. (2020, September 23). *តើមូលបត្រចែកចេញជាប៉ុន្មាន?* Retrieved from https://www.facebook.com/kakcentkh/posts

៨. Bajaj Finserv. (2025, June, 13). *What is Trading?* Retrieved from https://share.google/kbMLd0ATKiZRWnrGb

៩. Investopedia. (2024, May, 31). *What is Trading?* Retrieved from https://share.google/shFKMj9DUnSzQPeqc

១០. IG. (2021). *What is Trading?* Retrieved from https://share.google/xnsxlcIxQDquyJl9D

# ឧបសម្ព័ន្ធ

ផ្សារមូលបត្រកម្ពុជា

CSX






វិទ្យាស្ថាន វ៉ាន់ដា
VANDA INSTITUTE
វិស័យមូលបត្រនៅកម្ពុជា
Securities Sector in Cambodia


ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS
វិទ្យាស្ថាន វ៉ាន់ដា
VANDA INSTITUTE
សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ
ការជួញដូរមូលបត្រនៅកម្ពុជា
ជំនាញៈ គណនេយ្យ
រាជធានីភ្នំពេញ - ឆ្នាំ២០២១
PHNOM PENH - 2021


វិទ្យាស្ថាន វ៉ាន់ដា
VANDA INSTITUTE
សេចក្តីផ្តើមនៃនីតិ
INTRODUCTION TO LAW


សេដ្ឋកិច្ច
4.0
010.216
IA.PP/2023
ENCE MAGAZINE
លេខទី២ ២០២៣